# មតិស្វាគមន៍របស់ឯកឧត្តម ឯកអគ្គរាជទូត គូម៉ាម៉ារូ យូជិ



ជំរាបសួរ!

ខ្ញុំឈ្មោះ**គូម៉ាម៉ារូ យូជិ** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។ សូមស្វាគមន៍មកកាន់គេហទំព័រ របស់ស្ថានទូតជប៉ុននៅកម្ពុជា ។

នៅឆ្នាំកន្លងទៅថ្មីៗនេះកម្ពុជាទទួលបាននូវសមិទ្ធិផលគួរអោយកត់សម្គាល់នៅក្នុងកំរិតអភិវឌ្ឍ និងជោគជ័យជាច្រើន ដែលបានបំរើដល់តួនាទីជាប្រធានអាស៊ានកាលពីឆ្នាំមុន។ បច្ចុប្បន្នកម្ពុជាបានបង្ហាញនូវបម្លាស់ប្តូរមុខមាត់ដ៏ច្រើនជាមួយនិងការរីកចំរើនដ៏ខ្លាំងក្លាដែលមិនធ្លាប់មានពីមុន និងការពង្រីកសេដ្ឋកិច្ចរបស់ខ្លួនជាមួយនិងនិន្នាការកើនឡើងនៃការវិនិយោគពីប្រទេសជប៉ុន ដែលនេះសបញ្ជាក់អោយឃើញថាកម្ពុជាជារោងចក្រដ៏សំខាន់មួយនៅក្នុងពិភពលោក។
ក្នុងនាមជាតំណាងមួយរូបរបស់ប្រទេសជប៉ុន ខ្ញុំមានកិត្តិយសក្នុងការទទួលខុសត្រូវនៅក្នុងពេលវេលាដ៏រីករាយ នៃឱកាសទំនាក់ទំនងការទូតរវាងជប៉ុន និងកម្ពុជា។

ទំនាក់ទំនងការទូតរវាងជប៉ុន និងកម្ពុជាត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៥៣។ ចាប់តាំងពីពេលនោះមក ជាពិសេសនៅដើមទស្សវត្សទី៩០ ជប៉ុនបានផ្តល់នូវជំនួយផ្សេងៗគ្រប់ប្រភេទដើម្បីកសាងនិងអភិវឌ្ឍប្រទេសកម្ពុជា ដូចជាការចូលរួមដោយកងកម្លាំងស្វ័យការពារជប៉ុន ក្នុងដំណើរការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិដែលជាសកម្មភាពក្រៅប្រទេសលើកដំបូងរបស់កងកម្លាំងស្វ័យការពារជប៉ុន ការអនុវត្តគម្រោងជំនួយផ្សេងៗដោយរដ្ឋាភិបាលនិង អង្គការក្រៅរដ្ឋាភិ

បាលជប៉ុន កិច្ចសហប្រតិបត្តិការក្នុងការអភិរក្ស និងការថែទាំប្រាសាទអង្គរ ការចូលរួមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាដើម។

ឆ្នាំមុន មានព្រះរាជទស្សនកិច្ចរបស់ព្រះរាជទាយាទ ព្រមទាំងមានដំណើរទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រីជប៉ុន **ឈូដា** និងរដ្ឋមន្ត្រីការបរទេស **ហ្គេមបា** (កាលពីពេលនោះ) ហើយនៅដើមឆ្នាំនេះ យើងក៏ទទួលបាននូវព្រះរាជទស្សកិច្ចរបស់ព្រះអង្គម្ចាស់ **អាគីស៊ិណូ** មកកាន់ប្រទេសកម្ពុជា ដែលដំណើរយាងទស្សនកិច្ចនេះពិតជាបានពង្រឹងនូវទំនាក់ទំនងល្អរវាងរាជវង្សានុវង្ស នៃប្រទេសទាំងពីរក៏ដូច ជាអភិវឌ្ឍន៍នូវទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងជប៉ុននិងកម្ពុជានៅក្នុងវិស័យនយោបាយសេដ្ឋកិច្ចនិងវប្បធម៌ ជាដើម។

មួយវិញទៀត ឆ្នាំនេះជាឆ្នាំរំលឹកខួបអនុស្សាវរីយ៍៦០ឆ្នាំនៃការបង្កើតទំនាក់ទំនងការទូតរវាងជប៉ុន និងកម្ពុជា យើងនឹងរៀបចំនូវព្រឹត្តិការណ៍វប្បធម៌ផ្សេងៗ នៅក្នុងប្រទេសកម្ពុជាដើម្បីរំលឹកខួបអនុស្សាវរីយ៍មិត្តភាពនេះ។

ជាងនេះទៅទៀតប្រទេសជប៉ុនក៏បានយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍតំបន់ទន្លេមេគង្គរួមទាំងប្រទេសកម្ពុជានិងផ្តោតទៅលើការពង្រឹងទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសក្នុងតំបន់។

ស្ថានទូតរបស់យើងរួមជាមួយនិងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ប្រចាំនៅកម្ពុជា អង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុន (JETRO) ក្រុមហ៊ុនជប៉ុន ព្រមទាំងប្រជាជនជប៉ុនដែលរស់នៅក្នុងប្រទេសកម្ពុជា នឹងខិតខំប្រឹងប្រែងពង្រឹងទំនាក់ទំនងទ្វេរភាគីរវាងកម្ពុជា និងជប៉ុន។ ខ្ញុំក៏សូមស្វាគមន៍ដល់ប្រជាជនជប៉ុនមកពីក្រៅប្រទេសកម្ពុជាចូលមកកាន់និងធ្វើទស្សនកិច្ចព្រមទាំងធ្វើការជាមួយយើងដើម្បីជំរុញនូវមិត្តភាព និងទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរផងដែរ។